# អនុក្រឹត្យ លេខ ០៨ អនក្រ.បក
# ស្តីពី
# ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកំពង់ឆ្នាំង ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទីកសាប ក្នុងខេត្តកំពង់ឆ្នាំង ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ ៧ . ១៣. ១៤ .១៥ . ១៨. ១៩. និងលេខ ២0 ចាប់ពីរដូវនេសាទ ឆ្នាំ ២00១-២00២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តកំពង់ឆ្នាំង និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកំពង់ឆ្នាំង ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងក្លែក | | | | | |
| ១ | ៧ ៨៥១ | 0 | ៧ ៨៥១ | 0 | |
| ២ | ៣ ៥២៨ | ២២0 | ៣ ៣0៨ | ៦.២៣ | |
| ៣ | ៩២៩ | 0 | ៩២៩ | 0 | |
| ៤ | ២ ៤៤៧ | ៧៤៧ | ១ ៧00 | ៣0.៥២ | |
| ៥ | ៤ ៧១៨ | ១៩៣ | ៤ ៥២៥ | ៤.00 | |
| ៦ | ៥ ៦១៣ | ២៣៤ | ៥ ៣៧៩ | ៤.១៦ | |
| ៧ | ២១៣ | ២១៣ | 0 | ១00 | លុបចោល |
| ៨ | ២ ១៣0 | ២២ | ២ ១0៨ | ១.00 | |
| ៩ | ៤0៧ | ៧៦ | ៣៣១ | ១៨. ៦៧ | |
| ១0 | ១៦ ៩៥១ | ៨៣២ | ១៦ ១១៩ | ៤.៩0 | |
| ១១ | ២ ២៨៥ | ៥ | ២ ២៨0 | 0.២១ | |
| ១២ | ៥៥៣ | ១៨២ | ៣៧១ | ៣២ .៩១ | |
| ១៣ | ១ ៨៧៤ | ១ ៨៧៤ | 0 | ១00 | លុបចោល |
| ១៤ | ២ ៣១៥ | ២ ៣១៥ | 0 | ១00 | លុបចេញ |
| ១៥ | ៥ ៦៥៤ | ៥ ៦៥៤ | 0 | ១00 | លុបចេញ |
| ១៦ | ៧៥៣ | ៥៧0 | ១៨៣ | ៧៥.៦៩ | |
| ១៧ | ១៧0 | ១៧0 | 0 | ១00 | លុបចោល |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ២ ៤៣៨ | ២ ៤៣៨ | 0 | ១០០ | លុបចេញ |
| ១៩ | ១ ៤២៧ | ១ ៤២៧ | 0 | ១០០ | លុបចោល |
| សរុប ១៩ | ៦២ ២៥៦ | ១៧ ១៧២ | ៤៥ ០៨៤ | ២៧.៥៨ | |

**មាត្រា ២ ._**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុំហ៊ុំហែងយកទៅលក់ ឬ ផ្តល់អោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ ._**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ ._**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

* * *